# យុត្តិធម៌សម្រាប់ខាលពិឃាត

នៅថ្ងៃទី២០ ខែឧសភា រៀងរាល់ឆ្នាំ ប្រជាជនកម្ពុជាជាច្រើននាក់មកជួបជុំគ្នានៅបូជនីយដ្ឋានមួយនៅទីក្រុងញូវរីករដ្ឋញូវជើស៊ី ដើម្បីរំឭកការចងចាំអំពីរបបប្រល័យពូជសាសន៍ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ នៅក្នុង"ទិវាចងកំហឹង" មនុស្សម្នាមកកកុញដើម្បីស្តាប់ប្រសាសន៍របស់មន្ត្រីប្រចាំតំបន់ និងអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមថ្លែងពីអំពើឃោរឃៅនិងទុក្ខវេទនាដែលអ្នកទាំងនោះបានឆ្លងកាត់ពី"គុកឥតជញ្ជាំង" ។

អ្នកចូលរួមមួយចំនួនយំខ្សឹកខ្សួលនៅពេលព្រះសង្ឃធ្វើពិធីសូត្រមន្តឧទ្ទិសដល់ព្រលឹងអ្នកស្លាប់ និងនៅពេលស្តាប់ព្រឹត្តិរឿងរ៉ាវដែលស្រដៀងគ្នានឹងខ្សែជីវិតរបស់ខ្លួនហើយធ្វើឲ្យខ្លួននឹកដល់ការឈឺចាប់កាលពីពេលកន្លងមក ។ អ្នកចូលរួមមួយចំនួនទៀត ពុះកញ្ជ្រោលដោយកំហឹង ។ កាលពីមុន អ្នកចូលរួមបានកសាងជារូបសំណាករបស់ ប៉ុល ពត និងអ្នកគ្រាំទ្រ រួចហើយទាត់ធាក់ និងដុតភ្លើងបំផ្លាញនៅចំពីមុខបដាដែលសរសេរថា ៖ "ត្រូវចងចាំជីវិតក្រោមអំណាច ប៉ុល ពត ដែលជាអ្នកសម្លាប់ប្រជាជនកម្ពុជា" ។

ដោយទិវានេះបានផ្លាស់ប្តូរទៅតាមចរន្តនយោបាយនៅកម្ពុជា ការប្រារព្ធពិធីបុណ្យរំឭកនៅឆ្នាំនេះគឺគួរឲ្យកត់សម្គាល់ជាងឆ្នាំមុនៗ ដោយសារមានការសង្កត់ធ្ងន់លើបញ្ហាយុត្តិធម៌ ។ នៅក្នុងពេលដំណាលគ្នានេះដែរ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី បានប្រកាសជាផ្លូវការនូវឈ្មោះចៅក្រមនិងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិដែលនឹងបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។

តុលាការនេះបានផ្តើមដំណើរការនៅដើមរដូវស្លឹកឈើជ្រុះ (នៅរវាងខែកញ្ញានិងខែធ្នូ) ពេលដែលសហព្រះរាជអាជ្ញាជនជាតិកម្ពុជានិងកាដាណាចាប់ផ្តើមស៊ើបអង្កេតរឿងក្តី ។ យ៉ាងណាមិញ តុលាការប្រឈមមុខនឹងឧបសគ្គចម្បងមួយចំនួនដូចខាងក្រោម ៖

**ចុងចោទមានវ័យជរា** ៖ អតីតមេដឹកនាំខ្មែរក្រហមជាច្រើនរូបដូចជា "បងធំទីពីរ" នួន ជា អាយុ៧៨ឆ្នាំ, អតីតប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន អាយុ៧៤ឆ្នាំ, និងអតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស អៀង សារី អាយុ៧៦ សុទ្ធតែស្ថិតនៅក្នុងវ័យជរា និងមានសុខភាពទ្រុឌទ្រោម ។ អតីតមេដឹកនាំខ្មែរក្រហមទាំងអស់នេះអាចស្លាប់ដោយមិនបានទទួលការកាត់ទោសដូចករណីការស្លាប់របស់ ប៉ុល ពត កាលពីឆ្នាំ១៩៩៨ ។ ការស្លាប់របស់ ស្លូបូដាន មីឡូស៊ីវិក ក្នុងអំឡុងពេលសវនាការនៅទីក្រុងហេក កាន់តែបង្ហាញឲ្យឃើញនូវភាពបន្ទាន់ក្នុងការនាំឧក្រិដ្ឋជនទៅកាត់ទោសឲ្យកាន់តែឆាប់តាមដែលអាចធ្វើទៅបាន ។

**កង្វះខាតថវិកា** ៖ ខណៈដែលមានថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការតុលាការ ខាងភាគីកម្ពុជានៅខ្វះថវិកា៩,៦លានដុល្លារទៀត ដើម្បីបគ្រ្គប់ចំនួនថវិកាសរុប៥៦,៣លានដុល្លារ សម្រាប់ដំណើរការតុលាការក្នុងរយៈពេលបីឆ្នាំ ។ នេះជាចំនួនថវិកាដែលប្រទេសក្រីក្រមួយនេះមិនអាចចំណាយបានឡើយ ។ សហរដ្ឋអាមេរិកដែលមិនទាន់បានរួមវិភាគទានថវិកាមួយសេនណានៅឡើយនោះ អាចសម្រួលស្ថានភាពនេះបានដោយចេញបគ្រ្គប់ទឹកប្រាក់ដែលនៅខ្វះខាត ។

**ការផ្សព្វផ្សាយពត៌មានទៅក្នុងស្រទាប់ប្រជាជន** ៖ ប្រជាជនកម្ពុជាភាគច្រើន ជាពិសេសអ្នករស់នៅតំបន់ដាច់ស្រយាល មិនបានដឹងថាសវនាការបម្រុងនឹងកើតមានឡើងឡើយ ឬបើទោះបីជាគាត់បានដឹងព្រឹត្តអំពីតុលាការនេះក៏ដោយ ក៏គាត់នៅមានការយល់ដឹងតិចតួចអំពីដំណើរការនេះ ។ អង្គការមិនមែនរដ្ឋាភិបាលដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងធ្វើការយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានស្តីអំពីតុលាការ ប៉ុន្តែការខំប្រឹងប្រែងនេះទាមទារការឧបត្ថម្ភពេញទំហឹងពីម្ចាស់ជំនួយអន្តរជាតិ ។

**ប្រព័ន្ធតុលាការកម្ពុជា** ៖ មានការព្រួយបារម្ភខ្លាំងអំពីបញ្ហាថា បុគ្គលិកច្បាប់មិនទាន់មានការហ្វឹកហ្វឺន និងមិនទាន់មានឯករាជ្យភាពគ្រប់គ្រាន់នៅឡើយ ។ បញ្ហានេះអាចបណ្តាលឲ្យតុលាការស្ថិតនៅក្រោមឥទ្ធិពលរបស់ថ្នាក់ដឹកនាំកម្ពុជា ហើយជាលទ្ធផលតុលាការនឹងមិនអាចឆ្លើយតបទៅនឹងបទដ្ឋានច្បាប់អន្តរជាតិ ។ ការព្រួយបារម្ភមានកាន់តែខ្លាំងនៅពេលដែលបញ្ជីរាយនាមមន្ត្រីចៅក្រម មានឈ្មោះចៅក្រមមួយចំនួនដែលមានទំនាក់ទំនងជិតស្និទ្ធនឹងគណបក្សប្រជាជនកម្ពុជា ក្នុងនោះក៏មានឈ្មោះឧត្តមសេនីយ៍មួយរូបដែលជាសមាជិកគណៈកម្មាធិការ

មជ្ឈិមនៃគណបក្សប្រជាជនកម្ពុជា និងធ្លាប់ជាចៅក្រមនៅក្នុងសវនាការពីរដែលមានភាពមន្ទិលរហូតដល់មានការវាយប្រហារពីគណបក្សប្រឆាំង ។

ទោះបីជាបញ្ហាទាំងនេះចាំបាច់ទាមទារការយកចិត្តទុកដាក់ជាបន្ទាន់ក៏ដោយ ក៏គ្មានបញ្ហាណាមួយអាចបញ្ឈប់ដំណើរការតុលាការនេះបានឡើយ ។ ប្រជាជនកម្ពុជាដែលខ្ញុំទើបតែបានជួបជជែកថ្មីៗនេះ បាននិយាយថាខ្លួនចង់បានតុលាការដើម្បីស្វែងយល់ថាតើមានអ្វីកើតឡើង ហើយហេតុអ្វីបានជារឿងនេះកើតឡើង ។ ប្រជាជនកម្ពុជាចង់ឃើញអតីតមេដឹកនាំខ្មែរក្រហមដែលកំពុងរស់នៅដោយសេរី ទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានប្រព្រឹត្តកន្លងមក ។

សហគមន៍អន្តរជាតិ ជាពិសេសសហរដ្ឋអាមេរិក គួរតែប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីឲ្យតុលាការនេះទទួលជោគជ័យ ។ ប្រហែលជានៅពេលណាមួយ ប្រជាជនកម្ពុជានឹងប្រារព្ធពិធីបុណ្យថ្មីមួយគឺ “ទិវាយុត្តិធម៌” ។

**អាឡិច ហ៊ីនតុន**